ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលជួបឯកឧត្តម Jang Yun Gon ឯកអគ្គរដ្ឋទូតស.ប.ប កូរ៉េ ប្រចាំនៅកម្ពុជា

******

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង១០:០០ ព្រឹក នៅទីស្តីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យឯកឧត្តម Jang Yun Gon ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

ដោយនេះជាជំនួបផ្លូវការលើកដំបូង **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានសំដែងនូវការស្វាគមន៍ និងការអបអរសាទរ ចំពោះការតែងតាំងរូបឯកឧត្តម Jang Yun Gon ជាឯកអគ្គរដ្ឋទូត ប្រចាំនៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរដែលត្រូវបានកសាងឡើងដោយព្រះករុណា **"ព្រះបរមរតនកោដ្ឋ"** ព្រះមហាវីរក្សត្រកម្ពុជា ជាមួយនឹងឯកឧត្តមសេនាប្រមុខ **គីម អ៊ីលស៊ុង** អតីតថ្នាក់ដឹកនាំកំពូលរបស់ស.ប.បកូរ៉េ និងបានគូសបញ្ជាក់ពីបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្តរក្សានូវទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអះអាងថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានត្រៀមខ្លួនរួចជាស្រេចក្នុងការ ផ្តល់កិច្ចសហការ និងការគាំទ្រដល់ឯកឧត្តមឯកអគ្គរដ្ឋទូត ក្នុងការបំពេញបេសកកម្មការទូតនៅកម្ពុជាឲ្យប្រព្រឹត្តទៅដោយរលូននិងជោគជ័យ។

ឯកឧត្តម Jang Yun Gon បានរំលឹកឡើងវិញពីចំណងទាក់ទងរវាងប្រទេសទាំងពីរ ដោយបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាពនេះ និងបានលើកឡើងថា ពិតមែនតែសភាពការណ៍នៅលើ ពិភពលោកមានការប្រែប្រួល ប៉ុន្តែទំនាក់ទំនងរវាងកម្ពុជា និងស.ប.បកូរ៉េ នៅតែមានលក្ខណៈល្អដដែលពុំមានអ្វីផ្លាស់ប្តូរឡើយ។

ឯកឧត្តម Jang Yun Gon បានជំរាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីបំណងប្រាថ្នារបស់ថ្នាក់ដឹកនាំស.ប.ប.កូរ៉េ ក្នុងការបន្តថែរក្សានិងពង្រីកទំនាក់ទំនងជាមួយព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម

ឯកអគ្គរដ្ឋទូត បានបញ្ជាក់ថា ក្នុងការបំពេញភារកិច្ចរបស់ឯកឧត្តមនៅកម្ពុជា ឯកឧត្តមនឹងខិតខំប្រឹងប្រែងដើម្បីរួមចំណែកក្នុងការអភិវឌ្ឍទំនាក់ទំនងទ្វេភាគីនេះ។

នៅក្នុងឱកាសនោះដែរ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានជំរាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** ដោយត្រួសៗ អំពីសមិទ្ធិផលដែលរដ្ឋាភិបាលស.ប.បកូរ៉េសម្រេចបាននៅក្នុងការកសាងប្រទេសជាតិខ្លួន ហើយនិងអំពីសភាពការណ៍នៅស.ប.ប.កូរ៉េ និងនៅឧបទ្វីបកូរ៉េទាំងមូល។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលស.ប.ប.កូរ៉េ ក្នុងការប្រកាន់ខ្ជាប់នូវការបង្រួបបង្រួមប្រទេសកូរ៉េទាំងពីរដោយសន្តិវិធី ហើយស.ប.ប.កូរ៉េបានត្រៀមខ្លួនរួចជាស្រេច សម្រាប់ការជួបចរចាដោយផ្ទាល់ជាមួយនឹងសាធារណរដ្ឋកូរ៉េ លើការបង្រួបបង្រួមប្រទេសកូរ៉េទាំងពីរ។

ជាការឆ្លើយតប **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានឯកភាពចំពោះការវាយតម្លៃរបស់ឯកឧត្តមឯកអគ្គរដ្ឋទូត ស្តីពីទំនាក់ទំនងទ្វេភាគីរបស់ប្រទេសទាំងពីរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផល ដែលរដ្ឋាភិបាលស.ប.ប.កូរ៉េ សំរេចបាននៅក្នុងការកសាងប្រទេសជាតិខ្លួនក្នុងរយៈកាលកន្លងមកនេះ។

ចំពោះបញ្ហានៅឧបទ្វីបកូរ៉េ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះការវិវត្តន៍នៃសភាពការណ៍នៅឧបទ្វីបកូរ៉េ និងបានលើកឡើងអំពីការគាំទ្ររបស់កម្ពុជា ចំពោះការប្តេជ្ញាចិត្តរបស់ស.ប.ប.កូរ៉េក្នុងការជំរុញឲ្យមានការបង្រួបបង្រួមនៃប្រទេសកូរ៉េទាំងពីរដោយសន្តិវិធី។ ចំពោះការប្រឈមនឹងអ្វីដែលស.ប.ប.កូរ៉េ ចាត់ទុកថាជាការគំរាមកំហែងពីខាងក្រៅ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានលើកឡើងពីបទពិសោធន៍របស់កម្ពុជា ហើយយល់ថា ដំណោះស្រាយត្រូវធ្វើឡើងដោយសន្តិវិធីតាមរយៈការចរចា ពុំមែនតាមរយៈការប្រឈមមុខដាក់គ្នា និងប្រើប្រាស់កម្លាំងឡើយ។

ទាក់ទងនឹងបញ្ហានុយក្លេអ៊ែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានពន្យល់ថា ដោយព្រះរាជាណាចក្រកម្ពុជា ជាសមាជិកមួយរបស់អង្គការសហប្រជាជាតិ ដូច្នេះកម្ពុជាចាំបាច់ត្រូវគោរពនិងអនុវត្តទៅតាមសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីអំពីការសាកល្បងអាវុធនុយក្លេអ៊ែររបស់ស.ប.ប.កូរ៉េ ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ ថ្ងៃទី១៨ ខែ មករា ឆ្នាំ២០១៧